auscam freedom project | terre des hommes stops child exploitation | APLE

លេខ៖.១០/២៣.........TdH NL

**សូមគោរពជូន**

**លោកជំទាវ ជូ ប៊ុនអេង**

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

***កម្មវត្ថុ៖*** គោរពស្នើសុំជួបសម្ភាសន៍ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយផ្ទាល់ ឬ តាមអនឡាញ ដោយទីប្រឹក្សាគម្រោងរយៈពេល ១ម៉ោង និង ៣០ នាទី ទៅតាមពេលវេលាដ៏សមគួរចន្លោះពីថ្ងៃទី ១១ ដល់ ១៧ ខែឧសភា ឆ្នាំ ២០២៣ ដើម្បីប្រមូលទិន្នន័យដើមគ្រាសំរាប់ការអនុវត្តន៍គម្រោងសុវត្ថិភាព និង សិទ្ធិកុមារតាមប្រព័ន្ធអនឡាញ ហៅកាត់ថា "**ស្រួល**" នៅក្នុងប្រទេសកម្ពុជា។

***យោង៖***

- អនុស្សរណៈនៃការយោគយល់រវាងក្រសួងការបរទេស និងសហប្រត្តិបត្តការអន្តរជាតិ និងអង្គការដែនដីមនុស្សហូឡង់ដ៏ -ប្រចាំកម្ពុជា ចុះនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២។
- អនុស្សរណៈនៃការយោគយល់រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អង្គការដែនដីមនុស្សហូឡង់ដ៏ -ប្រចាំកម្ពុជាស្ដីពី ការទប់ស្កាត់ការរំលោភបំពាន់ផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញចុះនៅថ្ងៃទី ២២ ធ្នូ ឆ្នាំ២០២២។

តាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមជម្រាបជូន **លោកជំទាវ** មេត្តាជ្រាបថា៖ អង្គការដែនដីមនុស្ស-ហូឡង់ដ៏ដែលហៅកាត់ថា(TdH NL) ជាអង្គការ អន្តរជាតិមួយដែលបានចុះបញ្ជីជាមួយក្រសួងការបរទេស និងសហប្រត្តិបត្តការអន្តរជាតិ។ អង្គការយើង ខ្ញុំបានធ្វើការ យ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ជ) តាមរយៈការចុះអនុស្សារណៈយោគយល់។ អង្គការដែនដីមនុស្ស-ហូឡង់ដ៏ មានទស្សនៈ វិស័យការពារ កុមារតាមរយៈការពារ និងលុបបំបាត់ការរំលោភបំពានលើកុមារ និងផ្ដល់អំណាចដល់កុមារក្នុងបញ្ចេញមតិរបស់ពួកគេ។

អង្គការយើងខ្ញុំមានសេចក្ដីសោមនស្សរីករាយដើម្បីជម្រាប **លោកជំទាវ** ពីគម្រោងសុវត្ថិភាព និងសិទ្ធិកុមារតាមប្រព័ន្ធអនឡាញ។ គម្រោងនេះមានគោលដៅចម្បង គឺការពារកុមារដោយមិនប្រកាន់ពណ៌សម្បុរ និន្នាការភេទ សាសនា ជាតិសាសន៍ និងសមត្ថភាព ពីការរំលោភបំពានតាមប្រព័ន្ធអនឡាញ

Scanned with CamScanner

auscam freedom project | terre des hommes stops child exploitation | APLE

ដោយរស់នៅក្នុងគ្រួសារ និងសហគមន៍សុវត្ថិភាពដោយមិនមានការប្រព្រឹត្តផ្លូវភេទតាមប្រព័ន្ធអនឡាញ។ គម្រោងនេះមានរយៈពេល៣ឆ្នាំក្រោមការគាំទ្រថវិកាពីក្រុមហ៊ុនឆ្នោតប៉ុស្តិ៍កូដនៅក្នុងប្រទេសហូឡង់ដ៍ ហើយអង្គការ TdH NL បានចាប់ផ្តើមគម្រោងចាប់ខែ វិច្ឆការ ឆ្នាំ២០២២ ដល់ ៣០ ខែតុលា ឆ្នាំ២០២៥។ អង្គការ TdH NL ជាអ្នកសម្របសម្រួលក្នុងការអនុវត្តគម្រោងដោយមានចូលរួមពី អង្គកាសកម្មភាពដើម្បីកុមារ និងអង្គការសេរីភាពកម្ពុជាអូស្ត្រាលី។ តាមរយៈគម្រោងនេះអង្គការ TdH NL និង ធ្វើការជាមួយ កុមារ និងសហគមន៍ ការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ វិស័យ និងស្ថាប័នឯកជន ផ្នែកអ៊ីនធឺណេតទាំងនៅថ្នាក់ជាតិ ក្រោមជាតិ និងថ្នាក់តំបន់។ អង្គការយើងខ្ញុំនិងធ្វើការសិក្សាស្រាវជ្រាវប្រមូលទិន្នន័យដើមគ្រាសំរាប់ការអនុតវត្តន៍គម្រោងសុវត្ថិភាព និងសិទ្ធិកុមារតាមប្រព័ន្ធអនឡាញ។

អាស្រ័យដូចនេះនាងខ្ញុំសូមគោរពស្នើរសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី**លោកជំទាវ** ដើម្បីជួបសម្ភាន់តាមកាលបរិច្ឆេទដូចក្នុងកម្មវត្ថុខាងលើ។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃអង្គារ ៥រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣

**ឯកសារភ្ជាប់ជូន៖**

- អនុស្សារណៈយោគយល់រវាងTdH NL និងក្រសួងការបរទេស ឆ្នាំ២០២២
- អនុស្សារណៈយោគយល់រវាងTdH NL និង គ.ជ.ប.ជ ឆ្នាំ២០២២
- ព័ត៌មានសង្ខេបពីគម្រោង
- កម្រងសំណួរជាភាសាខ្មែរ

**ព័ត៌មានលំអិត៖** សូមទំនាក់ទំនង លោក លាប ឆេងឡា មន្ត្រីសម្របសម្រួលកម្មវិធី ទូរស័ព្ទ: ០១១ ៤៣៧ ០៨០

**លោកស្រី ប៊ុស្រា ហ្សុលហ្វីការ** (Bushra Zulfiqar)
**តំណាងប្រចាំប្រទេស**(Country Representative)

ការសិក្សាដើមគ្រាស្តីពីការរក្សាសុវត្ថិភាព និងសិទ្ធិរបស់កុមារ

នៅលើប្រព័ន្ធអនឡាញ

កម្រងសំណួរសម្រាប់អ្នកផ្តល់សម្ភាសន៍ចំបង

មន្ត្រីរដ្ឋាភិបាល

| កូដកម្រងសំណួរ | | កាលបរិច្ឆេទនៃថ្ងៃសម្ភាសន៍៖ | |
|---|---|---|---|
| **ល.រ** | **សំណួរ** | **ចម្លើយ** | **កូដ** |
| K១ | ឈ្មោះអ្នកសម្ភាសន៍ | | |
| K២ | ឈ្មោះអ្នកផ្តល់បទសម្ភាសន៍<br>ភេទ<br>និងលេខទូរស័ព្ទទំនាក់ទំនង<br>(ជម្រើស) | ○ ប្រុស<br>○ ស្រី<br>○ ផ្សេង | ១<br>២<br>៣ |
| K៣ | ប្រភេទនៃអ្នកផ្តល់បទសម្ភាសន៍ចំបង | • មន្ត្រីរដ្ឋាភិបាល (ថ្នាក់ជាតិ)<br>• មន្ត្រីរដ្ឋាភិបាល (ថ្នាក់ក្រោមជាតិ)<br>• មន្ត្រីអនុវត្តច្បាប់ (ថ្នាក់ជាតិ) | ១<br>២<br>៣ |

| | | | |
|---|---|---|---|
| | | • មន្ត្រីអនុវត្តច្បាប់ (ថ្នាក់ក្រោមជាតិ) | ៤ |
| K៤ | តួនាទីនៃអ្នកផ្តល់បទសម្ភាសន៍ចំបង | • | |
| K៥ | របៀបនៃការសម្ភាសន៍ | • ផ្ទាល់មាត់<br>• អនឡាយ | ១<br>២ |
| K៦ | ទីតាំងសម្ភាសន៍ | • ផ្លូវលេខ៖ ភូមិ<br>• សង្កាត់៖ ខណ្ឌ<br>• ស្រុក៖ ក្រុង | |

**ការយល់ព្រម**

**ការណែនាំ៖**

មុនពេលចាប់ផ្តើមសម្ភាសន៍ សូមណែនាំខ្លួនរបស់អ្នក និងបង្ហាញពីគោលបំណងនៃការធ្វើអង្កេត។

**អ្នកសម្ភាសន៍៖**

"ជម្រាបសួរ! ខ្ញុំឈ្មោះ.................ជាផ្នែកមួយនៃការសិក្សាដើមគ្រាស្តីពីការរក្សាសុវត្ថិភាព និងសិទ្ធិរបស់កុមារនៅលើប្រព័ន្ធអនឡាយ។ ខ្ញុំកំពុងធ្វើការអង្កេតមួយជាមួយឪពុកម្តាយ និងកុមារនៅក្នុងតំបន់គោលដៅ។ ហេតុនេះហើយ ក្រុមការងារយើងខ្ញុំបានចាត់ទុកលោកលោកស្រីជាអ្នកផ្តល់ព័ត៌មានដ៏មានតម្លៃ។ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីប្រមូលទិន្នន័យ ដើម្បីជួយយើងឱ្យអនុវត្តគម្រោងនេះក្នុងរបៀបសមស្របបំផុត។ ជាក់លាក់ យើងខ្ញុំមានបំណងវិភាគពីចំណេះដឹង ឥរិយាបថ និងការអនុវត្តពាក់ព័ន្ធនឹងសុវត្ថិភាពកុមារអនឡាយដោយភាគីផ្សេងៗរួមទាំងឪពុកម្តាយ។

ដើម្បីជួយយើងក្នុងការប្រមូលព័ត៌មានពាក់ព័ន្ធនឹងគម្រោង

យើងស្នើសុំការចូលរួមរបស់លោកលោកស្រីក្នុងការអង្កេតការនេះ។

ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកលោកស្រី ដែលអាចចំណាយពេល ៦០ នាទី។

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងបំពេញកង្វះខាតចំណេះដឹង

ហើយលទ្ធផលពីការសិក្សាស្រាវជ្រាវនេះនឹងយកទៅប្រើប្រាស់សម្រាប់ការតស៊ូមតិ។

**មុនពេលចាប់ផ្តើមការអង្កេត**

មុនពេលបន្តទៅមុខទៀត ខ្ញុំសូមធានាថារាល់ចម្លើយរបស់លោកលោកស្រីនឹងត្រូវរក្សាជាការសម្ងាត់។

ការចូលរួមរបស់លោកលោកស្រីក្នុងការអង្កេតនេះគឺជាការស្ម័គ្រចិត្ត។ លោកលោកស្រី

មានសិទ្ធិបដិសេធមិនចូលរួម និងបញ្ឈប់ការសម្ភាសន៍នេះក្នុងពេលណាក៏បាន ឬរំលងសំណួរ

ដែលលោកលោកស្រីមិនចង់ឆ្លើយ។ សូមបញ្ជាក់ថាមិនមានចម្លើយខុស ឬត្រូវ។

មុនពេលខ្ញុំចាប់ផ្តើម ខ្ញុំសូមការយល់ព្រមពីលោកលោកស្រីក្នុងការចូលរួមការសម្ភាសន៍នេះ។

តើអ្នកយល់ព្រមចូលរួមក្នុងការសម្ភាសន៍នេះដែរឬទេ? បាទ/ចាស□ ទេ□

តើលោក លោកស្រីមានសំណួរដែរឬទេ?

តើពួកយើងអាចចាប់ផ្តើមបានឬទេ?

**កំណត់សំគាល់សម្រាប់អ្នកសម្ភាសន៍៖** ប្រសិនបើអ្នកចូលរួមមានអារម្មណ៍ថាមិនចង់ចូលរួម អរគុណអ្នកចូលរួម នឹងបញ្ចប់ការសម្ភាសន៍។ ប្រសិនបើអ្នកចូលរួមយល់ព្រម ចាប់ផ្តើមការសម្ភាសន៍នៅទីតាំងដែលអ្នក និងអ្នកចូលរួមគិតថាមានសុវត្ថិភាព។

| ល.រ | សំណួរ និងចម្លើយ |
| --- | --- |
| ១ | ដោយពិចារណាលើការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិត និងទូរស័ព្ទដៃចល័តប្រើប្រាស់ដោយកុមារនៅក្នុងប្រទេសកម្ពុជា សូមលោកលោកស្រីចែករំលែកការយល់ដឹងរបស់លោកលោកស្រីអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ពាក់ព័ន្ធនឹងការកើតមានឡើង រួមទាំងហានិភ័យលើស្ថានភាពផ្លូវចិត្ត និងសុខុមាលភាពរបស់កុមារ។ |

| | |
|---|---|
| ២ | ផ្អែកលើចំណេះដឹងនិងការយល់ដឹងរបស់លោកលោកស្រី<br>តើអ្វីជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការកំណត់ពីករណីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងយន្តការដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចបែបនេះ? |
| ៣ក<br><br><br><br><br><br><br>៣ខ | តើមានករណីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារចំនួនប៉ុន្មាន<br>ដែលត្រូវបានរាយការណ៍ដោយនាយកដ្ឋានរបស់លោកលោកស្រីក្នុងឆ្នាំ ២០២០ ២០២១ និង ២០២២?<br>២០២០៖<br>២០២១៖<br>២០២២៖<br><br><br>តាមការយល់ឃើញរបស់លោកលោកស្រី<br>តើមានការកើនឡើងនៃករណីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាយក្នុងអំឡុងពេលកូវីដ ១៩ បើប្រៀបធៀបទៅនឹងមុនពេលកើតមានឡើងនៃវិបត្តិកូវីដ ១៩? |

| | |
|---|---|
| | |
| ៤ក | តើមានយន្តការបញ្ជូនបន្តអ្វីខ្លះដែលកំពុងអនុវត្ត ដើម្បីទប់ស្កាត់ ការពារ<br>និងគាំទ្រដល់ជនរងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ? |
| ៤ខ | តើលោកលោកស្រីគិតថាយន្តការដែលកំពុងអនុវត្តមានប្រសិទ្ធភាពក្នុងការការពារកុមារដែរឬទេ?<br>ប្រសិនជាទេ តើលោកលោកស្រីមានមតិយោបល់អ្វីដើម្បីឱ្យការអនុវត្តមានប្រសិទ្ធភាព? |
| ៤គ | តើមានយន្តការអ្វីខ្លះដែលបានបង្កើតឡើងសម្រាប់ការចូលរួមរបស់កុមារក្នុងដំណើរការផ្លូវច្បាប់<br>នយោបាយ និងស៊ីវិលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ? |

| | |
|---|---|
| ៥ក | តើមានការផ្តល់ជំនួយអ្វីខ្លះដល់ជនរងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាយ? |
| ៥ខ | តើលោកលោកស្រីគិតថាការគាំទ្រអ្វីខ្លះដែលក្រុមគ្រួសារ រួមទាំងកុមារត្រូវការពីរាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាយនៅកម្ពុជា? |
| ៦ | សូមលោកលោកស្រីរៀបរាប់ពីឱកាសសម្រាប់សហគមន៍ចូលរួមក្នុងការសន្ទនាគោលនយោបាយ ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាយ? |

| | |
|---|---|
| ៧ | តាមការយល់ឃើញរបស់លោកលោកស្រី<br>តើអ្វីខ្លះជាកត្តាជំរុញឱ្យមានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាយប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា ? |

អរគុណអ្នកផ្តល់បទសម្ភាសន៍ចំបងចំពោះការចូលរួម និងផ្តល់មតិយោបល់របស់គាត់ ។